ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..................សហវ.......

# បទឧទ្ទេសនាម

## របស់

## បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

## ស្តីពី

## សេចក្តីព្រាង «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»

## វិមានសន្តិភាព, ថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៨

- សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ;
- សូមគោរពសម្តេចក្រឡាហោម, សម្តេចពិជ័យសេនា, ឯកឧត្តម, លោកជំទាវ, ឧបនាយករដ្ឋមន្ត្រី, ទេសរដ្ឋមន្ត្រី, រដ្ឋមន្ត្រី ;
- សូមគោរពអង្គគណៈរដ្ឋមន្ត្រីទាំងមូល !

ជាបឋម, តាងនាមគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក៏ដូចជាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ខ្ញុំបាទសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុញ្ញាតឱ្យដាក់របៀបវារៈស្តីពី **«សេចក្តីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»** ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និង អនុម័ត ជាយថាហេតុនាថ្ងៃនេះ ។ សេចក្តីព្រាង



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

«**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥**» គឺជាសមិទ្ធផលការងារមួយថ្មីទៀតនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំចង្អុលបង្ហាញ និង គាំទ្រជាប្រចាំដ៏ខ្ពង់ខ្ពស់ ពីសំណាក់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងឋានៈ**សម្តេច** ជាអគ្គមេបញ្ជាការតែមួយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាក្នុងការ-អភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង សេដ្ឋកិច្ចជាទូទៅ ។

មុននឹងឈានដល់ខ្លឹមសារនៃឯកសារ, ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនអង្គគណៈរដ្ឋមន្ត្រីថា សេចក្តីព្រាងនៃឯកសារនេះ ត្រូវបានរៀបចំឡើងដោយ **ក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ក្រោមក្របខ័ណ្ឌនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ហើយត្រូវបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធគន្លឹះៗ ជាបន្តបន្ទាប់ ។ លើសពីនេះ, ដោយសារឯកសារនេះមានចរិតជាយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ជាមូលដ្ឋាននៃការកែទម្រង់ប្រព័ន្ធថវិកាក្នុងរយៈពេលវែង, ខ្ញុំបាទក៏បានដឹកនាំកិច្ចប្រជុំអន្តរក្រសួងមួយលើកទៀត កាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ នៅក្នុងក្របខ័ណ្ឌនៃគណៈ-កម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឆ្លងការពិភាក្សា, ប្រមូលធាតុចូល, និង អនុសាសន៍បន្ថែមទៀត, ក្នុងកម្រិតនយោបាយ និង គោលនយោបាយ, សំដៅធ្វើឱ្យសេចក្តីព្រាងយុទ្ធសាស្ត្រនេះ កាន់តែត្រូវបានកែលម្អ ។

ក្នុងន័យនេះ, គួរកត់សម្គាល់ថា ដំបូងឡើយសេចក្តីព្រាងឯកសារនេះ ត្រូវបានគ្រោងដាក់ឈ្មោះថា *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៧-២០២៥»* ដោយសារសកម្មភាពជាក់ស្តែងមួយចំនួននៃការងារកែទម្រង់ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រនេះ បានចាប់ផ្តើមនៅក្នុងឆ្នាំ ២០១៧ រួចមកហើយ ។ ក៏ប៉ុន្តែ, ដោយសារយុទ្ធសាស្ត្រនេះ គឺជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលទាមទារឱ្យមាននូវការបង្កើនការយល់ដឹងឱ្យបានទូលំទូលាយនៅក្នុងរាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ការចូលរួម និង ភាពម្ចាស់ការ ក្នុងការ-អនុវត្តពីសំណាក់គ្រប់ក្រសួង-ស្ថាប័នទាំងអស់, **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានផ្តល់ការ-សម្រេចដ៏ខ្ពង់ខ្ពស់ ឱ្យដាក់ឯកសារនេះជារបៀបវារៈសម្រាប់ពិនិត្យ និង អនុម័ត នៅកិច្ចប្រជុំ

ពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃនេះ, និង បានអនុញ្ញាតឱ្យប្តូរចំណងជើងនៃឯកសារ ជា *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»* វិញ ដោយរក្សាទុកនៅខ្លឹមសារដើមទាំងស្រុង ហើយកែសម្រួលតែក្របខ័ណ្ឌពេលវេលាបន្តិចបន្តួចពាក់ព័ន្ធនឹងសកម្មភាពដែលត្រូវបន្តអនុវត្ត ប៉ុណ្ណោះ ។

លើមូលដ្ឋាននេះ, ដើម្បីជាព័ត៌មានសម្រាប់ការពិនិត្យ, ពិចារណា និង អនុម័តជាយថាហេតុ លើសេចក្តីព្រាងយុទ្ធសាស្ត្រនេះ, ខ្ញុំបាទសូមគោរពសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង អង្គគណៈរដ្ឋមន្ត្រីទាំងមូល ឧទ្ទេសនាមអំពីសាវតាខ្លះៗ និងខ្លឹមសារសង្ខេបនៃ «**សេចក្តីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥**» ដូចតទៅ÷

## ១- អំពីសាវតា

ចាប់តាំងពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងឆ្នាំ ២០០៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើននៅក្នុងការដ្ឋានកែទម្រង់នេះ, ជា-ពិសេស សម្រេចបានជាសារវ័ន្តនូវជំហានទី ១ គឺ «**ភាពជឿទុកចិត្តបាននៃថវិកា**» និង ជំហានទី ២ គឺ «**គណនេយ្យភាពហិរញ្ញវត្ថុ**» ។ បច្ចុប្បន្ននេះ, ការអនុវត្តជំហានទី ៣ គឺ «**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**» ក៏កំពុងមានវឌ្ឍនៈភាពល្អ ដោយត្រូវបានគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០២០, មុននឹងឈានទៅអនុវត្តជំហានទី ៤ គឺ «**គណនេយ្យភាពសមិទ្ធកម្ម**» ចាប់ពីឆ្នាំ ២០២១ ដល់ទៅឆ្នាំ ២០២៥ ។

គប្បីរំលឹកថា នៅពេលត្រៀមលក្ខណៈសម្រាប់អនុវត្តជំហានទី ៣, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានធ្វើវិសោធនកម្ម នៅក្នុងឆ្នាំ ២០០៨ ដើម្បីបើកច្រកឱ្យរាជរដ្ឋា-ភិបាលអាចចាប់ផ្តើមអនុវត្តសាកល្បង « *ថវិកាកម្មវិធី* » ។ ទន្ទឹមនេះ, នៅក្នុងឆ្នាំ ២០១៣, រាជរដ្ឋាភិបាលបានដាក់ចេញនូវឯកសារ *«ទស្សនទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០»* ដោយបានប្តេជ្ញាធ្វើការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធ

ថវិកាផ្អែកលើធាតុចូល និង មជ្ឈការ ឆ្ពោះទៅប្រព័ន្ធថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម និង វិមជ្ឈការ ក្នុងឆ្នាំ ២០២០ ។ ដោយផ្អែកតាមទស្សនទាននេះ, ***ថវិកាកម្មវិធី*** ត្រូវបានចាប់ផ្តើមអនុវត្តសាកល្បងពេញលេញចាប់ពីឆ្នាំ ២០១៥, ហើយនៅក្នុងឆ្នាំ ២០១៨ នេះ ត្រូវបានអនុវត្តពេញលេញគ្រប់ក្រសួង-ស្ថាប័នទាំងអស់ ។ ការអនុវត្ត ***ថវិកាកម្មវិធី*** គឺជាដំណើរការនៃការផ្លាស់ប្តូរឆ្ពោះទៅកាន់ប្រព័ន្ធថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម និង មានលក្ខណៈវិមជ្ឈការ ដោយក្រសួង-ស្ថាប័ននីមួយៗអាចមាន ***អង្គភាពថវិកា*** ច្រើន ។

ឆ្លងតាមបទពិសោធន៍នៃការអនុវត្តអស់រយៈពេលជាង ២ ឆ្នាំ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានកិច្ចសហការពីអ្នកជំនាញពាក់ព័ន្ធ បានធ្វើការសិក្សា និង វាយតម្លៃវឌ្ឍនភាពឡើងវិញ អំពីការអនុវត្ត **«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម»** ពីព្រោះ ចាប់តាំងពីពេលចាប់ផ្តើមមកដល់ពេលនេះ យើងធ្វើដំណើរបានពាក់កណ្តាលផ្លូវហើយ, ទន្ទឹមនឹងនេះ បរិការណ៍ជាអន្តរជាតិក៏មានការប្រែប្រួលជាច្រើនក្នុងអភិក្រមឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្ម ។ ការវាយតម្លៃជាបឋមបានផ្តល់នូវការសន្និដ្ឋានថា ការសម្រេចឱ្យបាន **«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម»** នៅឆ្នាំ២០២០ គឺមានមហិច្ឆតាខ្ពស់ពេក ។

អាស្រ័យហេតុនេះ, ខ្ញុំបាទបានចាត់តាំងក្រុមការងារបច្ចេកទេសមួយរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ដែលក្រុមការងារនេះស្ថិតនៅក្រោមការដឹកនាំកម្រិតគោលនយោបាយ ដោយ **ឯកឧត្តមរដ្ឋលេខាធិការ វង្សី វិស្សុត** និង ការដឹកនាំកម្រិតបច្ចេកទេស ដោយ **ឯកឧត្តមអនុរដ្ឋលេខាធិការ ចាន់ សុធី**) ឱ្យរៀបចំឯកសារយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ជាមូលដ្ឋាននៃការកែទម្រង់ប្រព័ន្ធថវិកាក្នុងរយៈពេលវែង, **ស្របទៅតាមឧត្តមានុវត្តអន្តរជាតិ និង តាមតថភាពជាក់ស្តែងនៃកម្ពុជា,** ក្នុងគោលបំណងកសាងប្រព័ន្ធថវិកាជាតិមួយប្រកបដោយប្រសិទ្ធភាព, គណនេយ្យភាព, និង តម្លាភាព ។

ដូច្នេះ, សេចក្តីព្រាងឯកសារ ***«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»*** នេះ ត្រូវបានរៀបចំឡើង ដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ដែលបានឆ្លងកាត់ការសិក្សា និង ដកស្រង់បទពិសោធន៍ ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ និង ពីបណ្តាប្រទេសមួយចំនួន, ជាពិសេសផ្អែកលើបទពិសោធន៍នៃការអនុវត្តការងារជាក់ស្តែង រយៈពេល ៣ ឆ្នាំ របស់កម្ពុជាផ្ទាល់, ក៏ដូចជាការចូលរួមចែករំលែកបទពិសោធន៍ពីអ្នក-ជំនាញការជាច្រើននាក់, ព្រមទាំងការផ្តល់មតិយោបល់ពីដៃគូអភិវឌ្ឍន៍សំខាន់ៗ ។ ទន្ទឹមនេះ, ឯកសារនេះបានឆ្លងកាត់ការពិភាក្សាជាច្រើនលើកច្រើនសារ នៅផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធគន្លឹះនានា ។ ជាសរុប, ***ការរៀបចំឯកសារយុទ្ធ-សាស្ត្រនេះ ត្រូវបានធ្វើឡើងក្រោមភាពជាម្ចាស់របស់កម្ពុជាទាំងស្រុង*** ។

**២- អំពីទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា**

ខ្ញុំបាទសូមអនុញ្ញាតបញ្ជាក់ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង អង្គគណៈរដ្ឋមន្ត្រី មេត្តាជ្រាបថា នៅពេលយើងនិយាយពីប្រព័ន្ធថវិកាសមិទ្ធកម្ម គឺយើងផ្តោតការយកចិត្តទុកដាក់លើ **«សូចនាករសមិទ្ធកម្ម»** ដែលជាលទ្ធផលនៃការងារដែលក្រសួង-ស្ថាប័ន និង រាជរដ្ឋាភិ-បាល គ្រោងនឹងសម្រេចឱ្យបាន ដោយប្រើប្រាស់កញ្ចប់ថវិកាដែលខ្លួនបានទទួល ។ ក្នុងន័យនេះ, ជាទ្រឹស្តី, សូចនាករសមិទ្ធកម្ម គឺជាមូលដ្ឋាននៃការវិភាជន៍ថវិកាដល់ក្រសួង-ស្ថាប័ន ។ ប្រសិនបើក្រសួង-ស្ថាប័ន សម្រេចបានសមិទ្ធកម្មតិច នឹងទទួលបានថវិកាតិច, ប្រសិនបើក្រសួង-ស្ថាប័នមិនមានសមិទ្ធកម្ម គឺមិនទទួលបានថវិកាតែម្តង ។ សូចនាករសមិទ្ធកម្មនឹងត្រូវបានភ្ជាប់ជាមួយនឹងសេចក្តីព្រាងច្បាប់ថវិកា ដើម្បីជាព័ត៌មាន និង ជាមូលដ្ឋានសម្រាប់ឆ្លុះ-បញ្ចាំងលទ្ធផលការងារដែលសម្រេចបាននៅឆ្នាំនីមួយៗ ។

ប៉ុន្តែ, ការសិក្សាពីបទពិសោធន៍អន្តរជាតិបានបង្ហាញថា ប្រព័ន្ធថវិកាសមិទ្ធកម្មអាចអនុវត្តតាម ៣ ម៉ូដែល គឺ÷

**ទី១)-ប្រព័ន្ធថវិកាបង្ហាញសមិទ្ធកម្ម** ÷ តាមម៉ូដែលនេះ, ព័ត៌មានសមិទ្ធកម្មមានបង្ហាញក្នុងឯកសារថវិកា ឬ ឯកសារផ្សេងៗរបស់រដ្ឋាភិបាល ។ ព័ត៌មានសមិទ្ធកម្មសំដៅដល់គោលដៅ ឬ លទ្ធផល ឬ ព័ត៌មានទាំងពីរមុខនេះដែលនឹងត្រូវបានបញ្ចូលជាសារវតាសម្រាប់គណនេយ្យភាព និង សម្រាប់កិច្ចពិភាក្សាអំពីបញ្ហាគោលនយោបាយសាធារណៈ ជាមួយស្ថាប័ន

នីតិប្បញ្ញត្តិ និង សាធារណៈជន ។ ក៏ប៉ុន្តែ, ព័ត៌មានសមិទ្ធកម្មទាំងនោះមិនមានឥទ្ធិពលជា-ផ្លូវការចំពោះការសម្រេចនានា នៅក្នុងដំណើរការរៀបចំថវិកានោះទេ ។

**ទី២)-ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ÷** តាមម៉ូដែលនេះ, ការរៀបចំកញ្ចប់ថវិកាមានការពាក់ព័ន្ធជាប្រយោលជាមួយនឹងសមិទ្ធកម្មដែលបានស្នើឡើង ឬ ដែលសម្រេចបានកន្លង-មក ដោយក្រសួង-ស្ថាប័ន ។ ព័ត៌មានសមិទ្ធកម្មមានតួនាទីសំខាន់, ប៉ុន្តែ មិនមែនជាទម្ងន់ ឬ ជាកត្តាកំណត់ដាច់ខាត សម្រាប់ធ្វើការសម្រេចលើការវិភាជថវិកានោះទេ ។ ក្នុងន័យនេះ, ព័ត៌មានសមិទ្ធកម្មមិនមែនជាមូលដ្ឋានតែមួយគត់នោះទេ, ប៉ុន្តែ ត្រូវប្រើគួបផ្សំជាមួយនឹងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងសេដ្ឋកិច្ច, នយោបាយ, និង អាទិភាពគោលនយោបាយសម្រាប់ការសម្រេចលើការវិភាជថវិកា ឬ ធនធាន ។

**ទី៣)-ប្រព័ន្ធថវិកាសមិទ្ធកម្មផ្ទាល់ ឬប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម ÷** តាមម៉ូដែលនេះ, ការវិភាជធនធានធ្វើឡើងដោយផ្ទាល់ និង ច្បាស់លាស់ ទៅតាមឯកតាសមិទ្ធកម្មដែលត្រូវសម្រេចបាន ដែលជាទូទៅគឺផ្តោតលើលទ្ធផលក្នុងឆ្នាំ ។

ជារួម, ម៉ូដែលទាំង ៣ ខុសគ្នានៅត្រង់កម្រិតនៃការប្រើប្រាស់សូចនាករសមិទ្ធកម្មតាមទម្ងន់ផ្សេងៗគ្នានៅក្នុងការវិភាជថវិកា ដោយម៉ូដែលទី ២ មានលក្ខណៈកណ្តាល គឺផ្តល់នូវភាពបត់បែន និង ទន់ភ្លន់ល្មម ក្នុងការប្រើប្រាស់ព័ត៌មានសមិទ្ធកម្ម, ពោលគឺ មិនធូរលុងពេក ដែលអាចនឹងនាំឱ្យការអនុវត្តថវិកាសមិទ្ធកម្មមិនសូវមានន័យ និង មិនរឹងត្អឹងពេក ដែលនាំឱ្យការអនុវត្តមានលក្ខណៈដូចជាគ្រឿងម៉ាស៊ីន (ឬគម្ពីរនិយម) ។

ដោយសារប្រទេសភាគច្រើនកំពុងអនុវត្តតាមម៉ូដែលទី ២ និង តាមការវាយតម្លៃអំពីបរិការណ៍, ល្បឿន, និង ជម្រៅនៃការកែទម្រង់បច្ចុប្បន្ន, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈយល់ថា កម្ពុជាគួរជ្រើសរើសយកប្រព័ន្ធ **«ថវិកា-ព័ត៌មានសមិទ្ធកម្ម»** ជាទិសដៅជាក់លាក់នៃការកែទម្រង់ប្រព័ន្ធថវិកា ដោយកំណត់យកគោលដៅពេលវេលាដែលត្រូវសម្រេចឱ្យបាននៅឆ្នាំ ២០២៥ ស្របតាមគោលដៅនៃជំហានទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## ៣-អំពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ និង ផែនទីចង្អុលផ្លូវ

ដើម្បីចំណេញពេលវេលា, ខ្ញុំបាទសូមគោរពអនុញ្ញាតរាយការណ៍អំពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា និង ផែនទីចង្អុលផ្លូវ រួមគ្នាតែមួយតែម្តង ដោយប្រមូលផ្តុំលើសមាសធាតុគន្លឹះចំនួន ៤ គឺ ÷ ១)-ការធ្វើផែនការកម្រិតយុទ្ធសាស្ត្រ (ថវិការយៈពេលមធ្យម); ២)-ការរៀបចំគម្រោង និង ការអនុម័តថវិកាប្រចាំឆ្នាំ; ៣)-ការអនុវត្តថវិកា និង ការត្រួតពិនិត្យហិរញ្ញវត្ថុ; និង ៤)-ការធ្វើរបាយការណ៍, ការតាមដាន, និង ការវាយតម្លៃ ។ បន្ទាប់មក, ខ្ញុំបាទនឹងគូសបញ្ជាក់អំពីក្របខ័ណ្ឌ និង គោលការណ៍សំខាន់ៗ សម្រាប់តម្រង់ទិសការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាផ្នែកនៃប្រព័ន្ធថវិកាជាតិ ។ ទន្ទឹមនឹងនេះ, ខ្ញុំបាទក៏នឹងគូសរំលេចពីភាពចាំបាច់នៃការកែទម្រង់ផ្នែកហេដ្ឋារចនាសម្ព័ន្ធគាំទ្រសំខាន់ៗ មួយចំនួនផងដែរ ។

### <u>៣.១-ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រ</u>

ការរៀបចំផែនការកម្រិតយុទ្ធសាស្ត្រនេះមានគោលបំណងសំខាន់ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកាពហុឆ្នាំ ឬ ថវិការយៈពេលមធ្យម, ជំរុញការប្រើប្រាស់ព័ត៌មានសមិទ្ធកម្មជាមូលដ្ឋានមួយសម្រាប់ការវិភាជថវិកា, និង បង្កើនភាពជាម្ចាស់ និង គណនេយ្យភាពនៃក្រសួង-ស្ថាប័នលើការរៀបចំថវិកា ។

កិច្ចការទាំងនេះ រួមបញ្ចូលនូវការរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឱ្យកាន់តែមានគុណភាព និង សុក្រឹតភាព ដោយមានកំណត់គោលដៅសារពើពន្ធសរុប, ពិដានឱនភាពថវិកា, ពិដានតាមប្រភេទចំណាយ និង តាមវិស័យ, និង ហានិភ័យថវិកា, **ព្រមទាំងលើកកម្ពស់កម្រិតនៃការសម្រេចដល់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី** ។ លើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំនូវក្របខ័ណ្ឌថវិការយៈពេលមធ្យម ដោយកំណត់ពិដាន

ដល់កម្រិតក្រសួង-ស្ថាប័ន, រាជធានី-ខេត្ត, ក្រុង-ស្រុក, ឃុំ-សង្កាត់, ទាំងចំណាយចរន្ត និង ចំណាយវិនិយោគ, សម្រាប់ **ដាក់ជូននាយករដ្ឋមន្ត្រីពិនិត្យ និង សម្រេច** ។ ពិដានថវិកានេះ គឺជាមូលដ្ឋានសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ន និង រាជធានី-ខេត្ត ។ ***កិច្ចការនេះ នឹងត្រូវចាប់ផ្ដើមអនុវត្តក្នុងឆ្នាំ ២០២១ ។***

ខ្ញុំបាទសូមគូសបញ្ជាក់ថា នៅប្រទេសជឿនលឿនភាគច្រើន, ការងារនេះ ត្រូវបាន អនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ, ប៉ុន្តែ នៅប្រទេសខ្លះ ការអនុម័តនេះត្រូវបានធ្វើលើ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ (ពោលគឺ កំណត់ពិដានថវិការួម) ហើយនៅប្រទេសខ្លះទៀត ការអនុម័តត្រូវបានធ្វើលើ ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ពោលគឺ កំណត់ពិដានថវិកាកម្រិតក្រសួង-ស្ថាប័ន) ។

### <u>៣.២- ការរៀបចំ និងការអនុម័តថវិកាប្រចាំឆ្នាំ</u>

ក្នុងពេលបច្ចុប្បន្ន, ការរៀបចំសេចក្ដីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ត្រូវបានធ្វើឡើងដោយ ផ្អែកលើធាតុចូល និង ឆ្លុះបញ្ចាំងដោយមានកម្រិត អំពីកម្មវិធីអាទិភាព និង សមិទ្ធកម្ម ដែល ត្រូវសម្រេចឱ្យបាន ។ គោលដៅសំខាន់ គឺការរៀបចំសេចក្ដីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ដោយ ផ្អែកលើកម្មវិធី និង ចំណាត់ថ្នាក់សេដ្ឋកិច្ចបំព្រួញ ដោយមានភ្ជាប់សូចនាករ ឬ ព័ត៌មាន សមិទ្ធកម្មសម្រាប់ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិពិនិត្យ និង អនុម័ត ។ ***កិច្ចការនេះ នឹងត្រូវបាន ចាប់ផ្ដើមអនុវត្តសាកល្បង*** ដោយដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ ក្នុង**ឆ្នាំ ២០២១** និង ដាក់ជូន ស្ថាប័ននីតិប្បញ្ញត្តិពិនិត្យ ក្នុង**ឆ្នាំ ២០២២** ហើយនឹងត្រូវបានអនុវត្តជាក្របខ័ណ្ឌគតិយុត្ត នៅ**ឆ្នាំ ២០២៤** ។ នៅ**ឆ្នាំ ២០២៥**, សេចក្ដីព្រាងច្បាប់ថវិកាប្រចាំឆ្នាំនឹងមានភ្ជាប់ជាមួយនូវ សូចនាករ ឬ ព័ត៌មានសមិទ្ធកម្ម ទៅតាមកម្មវិធីនីមួយៗ ថែមទៀត ។

នៅក្នុងកិច្ចដំណើរការថ្មីនេះ, ក្រសួង-ស្ថាប័នត្រូវមានកាតព្វកិច្ច «ការពារ» កម្មវិធី របស់ខ្លួន នៅក្នុងការពិភាក្សាដេញដោលថវិកា ដោយគណៈកម្មការជំនាញនៃស្ថាប័ននិតី-ប្បញ្ញត្តិ ដែលការពិភាក្សានោះនឹងប្រព្រឹត្តទៅតែមួយលើក និង នៅតែរដ្ឋសភាប៉ុណ្ណោះ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងទទួលខុសត្រូវក្នុងការការពារកញ្ចប់ថវិការបស់ក្រសួង-

ស្ថាប័ន និង កញ្ចប់ថវិកាតាមកម្មវិធី នៅគណៈកម្មការទី ២ និង នៅក្នុងកិច្ចប្រជុំពេញអង្គនៃស្ថាប័ននីតិបញ្ញត្តិ ។ *កិច្ចការនេះ នឹងត្រូវបានចាប់ផ្តើមអនុវត្តសាកល្បង ក្នុងឆ្នាំ ២០២២ ហើយបន្ទាប់ពីនោះ នឹងត្រូវបានអនុវត្តជាក្របខ័ណ្ឌគតិយុត្ត នៅឆ្នាំ ២០២៤។*

### ៣.៣- ការអនុវត្ត និង ការត្រួតពិនិត្យថវិកា

យុទ្ធសាស្ត្រនេះ មានគោលបំណងបង្កើនភាពទន់ភ្លន់ និង ភាពងាយស្រួលដល់ក្រសួង-ស្ថាប័ន តាមរយៈ÷ ១)-ការកាត់បន្ថយនីតិវិធីអនុវត្ត និង ស្វ័យប្រវត្តិកម្ម, ២)-ការផ្តល់សិទ្ធិសម្រេចក្នុងការអនុវត្តថវិកា, និង ៣)-ការធ្វើប្រតិភូកម្មលើការងារត្រួតពិនិត្យថវិកា ។ ក្នុងន័យនេះ, នៅពេលច្បាប់ថវិកាត្រូវបានអនុម័តរួច, ឥណទានថវិកានឹងក្លាយជាមូលដ្ឋាននៃការអនុញ្ញាតឱ្យបញ្ជាចំណាយពេញមួយឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលចំណាយនេះត្រូវធ្វើឡើងជាកម្មវិធីចំណាយប្រចាំត្រីមាស/ឆមាស ស្របតាមគោលការណ៍កំណត់, លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំ, មិនមានគោលការណ៍/គោលរបបច្បាស់លាស់ និង/ ឬ មានវេទយិតភាពខ្ពស់ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំបង្កើតយន្តការត្រួតពិនិត្យថវិកា ដែលប្រមូលផ្តុំនូវមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និង កិច្ចលទ្ធកម្ម អមផ្ទាល់នៅក្រសួង-ស្ថាប័ន ហៅថា **«អភិបាលថវិកា»** ដែលមានលក្ខណៈសាមញ្ញ, មានសិទ្ធិស្វ័យសម្រេច និង មានការទទួលខុសត្រូវខ្ពស់, ព្រមទាំងមានគណនេយ្យភាពច្បាស់លាស់ ស្របតាមទិសដៅនៃថវិកាសមិទ្ធកម្ម ។ ទន្ទឹមនឹងការងារត្រួតពិនិត្យ, **អភិបាលថវិកា** មានកាតព្វកិច្ចជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារគ្រប់គ្រងថវិកានៅនឹងកន្លែង (នៅក្រសួង-ស្ថាប័ន) ព្រមទាំងការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ហើយបើមិនអាចដោះស្រាយបាននៅនឹងកន្លែង, ទើបរាយការណ៍មកជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈសមត្ថកិច្ចជំនាញពាក់ព័ន្ធ ។ មន្ត្រីអភិបាលថវិកាស្ថិតនៅក្រោមបញ្ជា និង ត្រូវបានតែងតាំង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយត្រូវមានក្របខ័ណ្ឌ, ជំនាញ-

វិជ្ជាជីវៈ និង អាណត្តិការងារច្បាស់លាស់ ។ ***កិច្ចការនេះ ត្រូវចាប់ផ្តើមអនុវត្តជាបណ្តើរៗ ពីឆ្នាំ ២០២២ និង អនុវត្តពេញលេញ នៅឆ្នាំ ២០២៥ ។***

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងធ្វើប្រតិភូកម្មសិទ្ធិអំណាច និង ការទទួលខុសត្រូវនៃកិច្ចលទ្ធកម្មទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយពង្រឹងការធ្វើសុខដុមនីយកម្មនៃកិច្ចលទ្ធកម្ម, ពង្រឹងតួនាទីនិយ័តករ និង ពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយជម្លោះ ។ ***កិច្ចការនេះ ត្រូវចាប់ផ្តើមអនុវត្តជាបណ្តើរៗ ពីឆ្នាំ ២០១៨ តទៅ និង ឈានទៅអនុវត្តពេញលេញ នៅឆ្នាំ ២០២៥ ។***

ការធ្វើសាមញ្ញកម្មក្របខ័ណ្ឌ និង នីតិវិធីនៃការត្រួតពិនិត្យ និង ការបើកផ្តល់ នឹងត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS), ចំណែកការទូទាត់សាច់ប្រាក់ ក៏នឹងត្រូវបានធ្វើតាមរយៈការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិច (E-Transfer) ផងដែរ ។ ប្រការនេះ នឹងតម្រូវឱ្យមានការពិនិត្យឡើងវិញនូវតួនាទី និង មុខងារនៃគណនេយ្យករសាធារណៈ ក្នុងពេលរៀបចំថ្មីនូវបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងគណនេយ្យករសាធារណៈ ***ដែលត្រូវបានគ្រោងធ្វើឱ្យរួចរាល់ ត្រឹមឆ្នាំ ២០២០*** ។

## ***៣.៤-ការតាមដាន និង វាយតម្លៃការអនុវត្តថវិកា***

នៅក្នុងផ្នែកនេះ, ប្រព័ន្ធរបាយការណ៍នឹងត្រូវបានពង្រឹងបន្ថែមទៀត ។ របាយការណ៍ហិរញ្ញវត្ថុ នឹងត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់កែសម្រួល ស្របតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ ( Modified Cash-IPSAS) ហើយស្របទៅតាមរបាយ-ការណ៍សមិទ្ធកម្មតាមកម្មវិធី និង អនុកម្មវិធី ។ ទន្ទឹមនេះ, ក្របខ័ណ្ឌសម្រាប់តាមដាន និង វាយតម្លៃសមិទ្ធកម្ម ក៏នឹងត្រូវបានរៀបចំឡើងវិញ តាមរយៈការកំណត់មុខងារ, សិទ្ធិអំណាច, និង កាតព្វកិច្ច ឱ្យបានច្បាស់លាស់រវាងក្រសួង-ស្ថាប័ន, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, អាជ្ញាធរសវនកម្មជាតិ, និង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ។ ***កិច្ចការទាំងពីរនេះ ត្រូវរៀបចំឱ្យបានរួចរាល់ នៅឆ្នាំ ២០២២, អនុវត្តសាកល្បង នៅឆ្នាំ ២០២៣ និង អនុវត្តពេញលេញ នៅឆ្នាំ ២០២៥ ។***

## <u>៣.៥-ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការកែទម្រង់</u>

ក្នុងចំណោមហេដ្ឋារចនាសម្ព័ន្ធគាំទ្រជាច្រើននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, មានការងារគាំទ្រជាអាទិភាពសំខាន់បី ដែលមានលក្ខណៈគ្រប់ដណ្តប់ និង ចាំបាច់សម្រាប់ការកែទម្រង់ប្រព័ន្ធថវិកា ពោលគឺ÷

១)-ការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ការរៀបចំនូវបទដ្ឋានគតិយុត្តពាក់ព័ន្ធឱ្យស្របតាមប្រព័ន្ធថវិកាថ្មី ÷ គោលបំណងនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ នេះ គឺសំដៅផ្តល់ភាពស្របច្បាប់ក្នុងដំណើរការរៀបចំថវិកាតាមប្រព័ន្ធព័ត៌មានសមិទ្ធកម្ម ។ ទន្ទឹមនេះ, បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការត្រួតពិនិត្យហិរញ្ញវត្ថុ និង គណនេយ្យករសាធារណៈ ក៏ដូចជានីតិវិធីលម្អិតសម្រាប់អនុវត្តថវិកា ក៏នឹងត្រូវបានរៀបចំឡើងវិញ ។ ***កិច្ចការទាំងនេះ ត្រូវសម្រេចឱ្យបានរួចរាល់ ក្នុងឆ្នាំ ២០២០ ។***

២)-ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលកំពុងតែត្រូវបានអនុវត្តក្នុងជំហានទី ២ នឹងត្រូវបានបន្តពង្រីកឱ្យគ្របដណ្តប់លើប្រតិបត្តិការទាំងអស់នៅក្នុងវដ្តថវិកា ដែលរួមមាន÷ ការរៀបចំគម្រោងថវិកា, ការអនុវត្តថវិកា, កិច្ចបញ្ជិកាគណនេយ្យ, ការធ្វើរបាយការណ៍, ការតាមដាន, និង សវនកម្ម ។ ប្រព័ន្ធនេះ នឹងជំរុញឱ្យមានការផ្លាស់ប្តូរនីតិវិធីការងារ។

៣)-ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និង ជំនាញក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ សមត្ថភាពជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ការវិភាគថវិកា, គណនេយ្យបង្គរ និង ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ, បច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ, កិច្ចលទ្ធកម្ម និង ការគ្រប់គ្រងគម្រោង, ព្រមទាំងការតាមដាន និង វាយតម្លៃ ។ល។ នឹងត្រូវបានលើកកម្ពស់បន្ថែមស្របទៅតាមនីតិវិធីការងារថ្មី ។ ជាមួយគ្នានេះ, ការជ្រើសរើស, ការតែងតាំង, ការលើកទឹកចិត្ត និង ការថែរក្សាធនធានមនុស្ស ក្នុងវិស័យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏នឹងត្រូវបានត្រួតពិនិត្យឡើងវិញផងដែរ ។

## ៣.៦- ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ជារួម, ពាក់ព័ន្ធនឹងផ្នែកនេះ, ខ្ញុំបាទសូមការអនុញ្ញាតគោរពជម្រាប **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និង អង្គគណៈរដ្ឋមន្ត្រី មេត្តាជ្រាបថា ការសិក្សាអំពីប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងប្រទេសជាច្រើនបានបង្ហាញថា ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិរបស់កម្ពុជាមានភាពស្រដៀងគ្នាច្រើនទៅនឹងប្រព័ន្ធរបស់ប្រទេសបារាំង ។ នៅក្នុងន័យនេះ, គំរូនៃប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិរបស់ប្រទេសបារាំង បានផ្តល់ជាមូលដ្ឋានទស្សនទានដ៏សំខាន់សម្រាប់យកមកគិតគូររៀបចំប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបរិបទរបស់កម្ពុជា ពិសេសការអនុវត្ត និង ការត្រួតពិនិត្យថវិកា ។ ចំពោះក្របខ័ណ្ឌពេលវេលាវិញ, យុទ្ធសាស្ត្រនេះមិនទាន់កំណត់ច្បាស់លាស់នៅឡើយ ដោយនឹងត្រូវកំណត់នៅពេលរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ តាមអភិក្រមដើរតាមការកែទម្រង់ប្រព័ន្ធថវិកាជាតិ, ដោយសម្របសម្រួលជាមួយការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ការកែទម្រង់រដ្ឋបាលសាធារណៈ ស្របតាមភាពចាំបាច់ និង តាមតថភាពជាក់ស្តែងរបស់កម្ពុជា ។

ឯកសារយុទ្ធសាស្ត្រនេះបានកំណត់ថា ***ប្រទេសកម្ពុជាមានតែប្រព័ន្ធថវិកាមួយប៉ុណ្ណោះ គឺ «ប្រព័ន្ធថវិកាជាតិ»*** ដោយប្រព័ន្ធថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថិតនៅក្នុងប្រព័ន្ធថវិកាជាតិនេះ ហើយមានលក្ខណៈជាអនុប្រព័ន្ធ ។ មានន័យថា ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ មានលក្ខណៈដូចគ្នាទៅនឹងប្រព័ន្ធថវិកាជាតិដែរ ប៉ុន្តែ មានលក្ខណៈសាមញ្ញ; ហើយជាគោលការណ៍, រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនឹងទទួលបាននូវសិទ្ធិស្វ័យសម្រេច និងត្រូវមានគណនេយ្យភាព នៅក្នុងការវិភាជ និង ការអនុវត្តថវិការបស់ខ្លួន ។ ទោះជាយ៉ាងនេះក្តី, ប្រព័ន្ធទាំងពីរនេះត្រូវធ្វើឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា, បំពេញឱ្យគ្នា, និង ប្រទាក់គ្នាទៅវិញទៅមក, តាមរយៈសមាហរណកម្មផែនការនីយកម្ម ឬ សុខដុមនីយកម្មកិច្ចដំណើរការធ្វើផែនការ ។

រូបភាពដ្យាក្រាមដែលកំពុងតែត្រូវបានបញ្ចាំងជូនពេលនេះ បង្ហាញពីក្របខ័ណ្ឌទស្សនទាននៃសមាហរណកម្មផែនការនីយកម្មនៃថវិកាថ្នាក់ជាតិ និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ខាងឆ្វេង, ផ្នែកវិសហមជ្ឈការ, គឺបង្ហាញពីខ្សែច្រវ៉ាក់នៃរចនាសម្ព័ន្ធចាត់តាំង, រចនាសម្ព័ន្ធកម្មវិធី និង រចនាសម្ព័ន្ធសមិទ្ធកម្មនៃក្រសួង-ស្ថាប័នថ្នាក់ជាតិ ។ នៅខាងស្តាំ, ផ្នែកវិមជ្ឈការ គឺបង្ហាញពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានបីថ្នាក់ និង មានស្វ័យភាពពីគ្នា; ប៉ុន្តែ ត្រូវផ្សារភ្ជាប់ទំនាក់ទំនងគ្នា, ប្រទាក់ក្រឡាគ្នា, ទៅតាមខ្សែច្រវ៉ាក់នៃរចនាសម្ព័ន្ធកម្មវិធី និង រចនាសម្ព័ន្ធសមិទ្ធកម្ម ដែលធ្វើឡើងតាមរយៈផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្ត ។ ទាំងផែនការយុទ្ធសាស្ត្រថវិកាក្រសួង-ស្ថាប័ន និង ទាំងផែនយុទ្ធសាស្ត្រថវិការាជធានី-ខេត្ត មានគោលដៅឈានទៅសម្រេចគោលនយោបាយជាតិតែមួយរួមគ្នា ។ ការធ្វើបែបនេះ គឺដើម្បីសន្សំសំចៃ និង លើកកម្ពស់ នូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានថវិកាជាតិដែលមានកំណត់ ។

ក្នុងន័យនេះ, ការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ នឹងត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការធ្វើសមារណកម្មនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលគ្របដណ្តប់ថវិការាជធានី-ខេត្ត, ក្រុង-ស្រុក, និង ឃុំ-សង្កាត់, ជាពិសេស ការបន្សុីគ្នាអំពីសមិទ្ធកម្ម, វដ្តថវិកា, ចំណាត់ថ្នាក់ថវិកា, ព្រមទាំងទម្រង់របាយការណ៍ ។ ទោះជាយ៉ាងនេះក្តី, ការធ្វើសមារណកម្មនេះ នឹងធានាផ្តល់សិទ្ធិស្វ័យសម្រេចក្នុងការវិភាជ និង អនុវត្តថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ជាពិសេស តាមរយៈការកែលម្អដំណើរការប្រឹក្សាយោបល់ និង ការសម្របសម្រួលរវាងក្រសួង-ស្ថាប័ន តាមរយៈមន្ទីរជំនាញរាជធានី-ខេត្ត ជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងតាមរយៈការជំរុញការបែងចែកមុខងារឱ្យកាន់តែច្បាស់លាស់ថែមទៀតរវាងរដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ទន្ទឹមនេះ, ការកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលមានដំណើរការល្អ និងបំពេញមុខងារគ្រប់ជ្រុងជ្រោយ រហូតដល់ថ្នាក់ក្រោមជាតិ គឺជាប្រការមិនអាចខ្វះបាន ។

ផ្អែកលើក្របខ័ណ្ឌទស្សនទានដូចបានរៀបរាប់ខាងលើ ***«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»*** បានផ្តល់ជាក្របខ័ណ្ឌតម្រង់ទិសសម្រាប់ការរៀបចំ ***យុទ្ធ-***

*សាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិដោយឡែក* ដោយគោរពគោលការណ៍សំខាន់ៗមួយចំនួន ដូចខាងក្រោម ÷

ទី១)- ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្ត នឹងផ្អែកទៅលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និង ក្របខ័ណ្ឌថវិការយៈពេលមធ្យម តែមួយជាមួយគ្នានឹងថ្នាក់ជាតិដែរ ។ ការរៀបចំថវិកាប្រចាំឆ្នាំ នឹងត្រូវផ្អែកលើកម្មវិធីដោយតម្រង់ទិសឆ្ពោះទៅរកការសម្រេចលទ្ធផលក្នុងឆ្នាំនៃកម្មវិធីនីមួយៗ ទន្ទឹមនឹងការធ្វើសមាហរណកម្មថវិកាចរន្ត និង ថវិកាមូលធន ។ ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនឹងមានតែមួយ ដែលរួមមាន÷ ថវិកាថ្នាក់ជាតិ និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។ ថវិការដ្ឋបាលរាជធានី-ខេត្ត នឹងឆ្លុះបញ្ចាំងជាសរុបតាមខេត្តនីមួយៗ ដោយចែកជាថវិកាចរន្ត និង ថវិកាមូលធន ជាឧបសម្ព័ន្ធនៃច្បាប់ ។ ដោយឡែក, ថវិការបស់រដ្ឋបាលក្រុង-ស្រុក និង ឃុំ-សង្កាត់ នឹងត្រូវឆ្លុះបញ្ចាំងជាទំហំសរុបដុល ដែលជាលទ្ធផលនៃការវិភាជលម្អិតតាមរដ្ឋបាលនីមួយៗ ដោយផ្អែកលើរូបមន្តបែងចែកជាក់លាក់ និង ផ្អែកលើសមិទ្ធកម្ម ។ ក្នុងពេលខាងមុខ, ខណៈដែលប្រព័ន្ធគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែត្រូវបានកែលម្អ, គោលការណ៍នៃការរៀបចំ និង អនុម័តថវិកា នឹងត្រូវពិនិត្យឡើងវិញ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ។

ទី២)- នៅក្នុងការអនុវត្តថវិកាថ្នាក់ក្រោមជាតិ, ការអនុញ្ញាតចំណាយថវិកាវិមជ្ឈការនឹងត្រូវបានធ្វើជាស្វ័យប្រវត្តិ បន្ទាប់ពីច្បាប់ថវិកាត្រូវបានអនុម័ត ស្របតាមកម្មវិធីចំណាយប្រចាំត្រីមាស/ឆមាស ដែលមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ការប្រគល់សិទ្ធិចាត់ចែងអនុវត្តថវិកាឱ្យដល់អង្គភាពប្រតិបត្តិនៅថ្នាក់ក្រោមជាតិ ។ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងត្រូវបានផ្តល់អំណាច និង ការទទួលខុសត្រូវរួម និង ដោយផ្ទាល់ ក្នុងការត្រួតពិនិត្យ ថវិកាមន្ទីរជំនាញ និង ថវិការដ្ឋបាលរាជធានី-ខេត្ត តាមរយៈការបង្កើតតួនាទីត្រួតពិនិត្យថវិកា ដែលប្រមូលផ្តុំមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និង កិច្ចលទ្ធកម្ម, ការត្រួតពិនិត្យការអនុវត្តចំណូលមិនមែនសារពើពន្ធ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

ទី៣)-រដ្ឋបាលក្រុង-ស្រុក និង រដ្ឋបាលឃុំ-សង្កាត់ នឹងទទួលបាននូវសិទ្ធិស្វ័យសម្រេច និង ការទទួលខុសត្រូវពេញលេញ នៅក្នុងការអនុវត្តថវិការបស់ខ្លួន ។ ប៉ុន្តែ ការអនុវត្តចំណាយនេះ គឺជាកម្មវត្ថុនៃការត្រួតពិនិត្យតាមក្រោយ ដោយរតនាគាររាជធានី-ខេត្ត ក្នុងមុខងារជាគណនេយ្យករសាធារណៈ ព្រមជាមួយនឹងការពង្រឹងជាយថាហេតុ នូវមុខងារអធិការកិច្ចហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ជាយន្តការប្រតិតុល្យការ (Check and balance) ។

ទី៤)-ជាមួយគ្នានេះ, ប្រព័ន្ធរបាយការណ៍នឹងត្រូវបានពង្រឹង ដោយក្នុងនោះរដ្ឋបាលឃុំ-សង្កាត់, ក្រុង-ស្រុក-ខណ្ឌ នឹងត្រូវរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តអនុកម្មវិធី និង សកម្មភាពការងាររបស់ខ្លួន ក្នុងទម្រង់ជាលទ្ធផលក្នុងឆ្នាំ ទៅក្រុមប្រឹក្សារៀងៗខ្លួន ។ ដោយឡែក, រដ្ឋបាលរាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបនៅកម្រិតកម្មវិធី ហើយរាយការណ៍ទៅក្រុមប្រឹក្សារបស់ខ្លួន, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, និង ក្រសួងមហាផ្ទៃ ។

### ៤- យន្តការអនុវត្ត និងហានិភ័យ

ដើម្បីជំរុញការអនុវត្ត **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»** នេះឱ្យបានជោគជ័យ, ផែនទីចង្អុលផ្លូវ និង បង្គោលចរទាំងឡាយដែលមានចែងនៅក្នុងយុទ្ធសាស្ត្រនេះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ និង ដំណាក់កាលទី ៤ តាមរយៈផែនការសកម្មភាពរួម ។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័នទាំងអស់ ត្រូវរៀបចំផែនការសកម្មភាពជាក់លាក់ និង តាមពេលកំណត់ ដើម្បីចូលរួមអនុវត្តការកែទម្រង់ប្រព័ន្ធថវិកា ។ ជាមួយគ្នានេះ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងបន្តដើរតួនាទីត្រួតពិនិត្យ និង តាមដានជាប្រចាំ នូវវឌ្ឍនភាពនៃការកែទម្រង់ប្រព័ន្ធ និង សម្របសម្រួលឱ្យបានកាន់តែល្អ និង រលូនជាមួយនឹងការកែទម្រង់ពាក់ព័ន្ធដទៃទៀត, ទាំងការសម្របសម្រួលក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ទាំងការសម្របសម្រួលជាមួយនឹងការដ្ឋានកែទម្រង់ពាក់ព័ន្ធទាំងពីរផ្សេងទៀត ។

ក្នុងន័យនេះ, ការអនុវត្តនូវការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាអាចជួបនឹងហានិភ័យមួយចំនួន ពីព្រោះថា ការកែទម្រង់ប្រព័ន្ធថវិកាមានទំនាក់ទំនងយ៉ាងជិតស្និត និង ពឹងផ្អែកគ្នាទៅវិញទៅមក ជាមួយនឹងការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ព្រមទាំងការកែទម្រង់ដទៃៗ ទៀតនៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការពន្យារពេល ឬ ភាពមិនស៊ីចង្វាក់គ្នានៃការកែ-ទម្រង់ទាំងនេះ អាចនឹងធ្វើឱ្យការកែទម្រង់ប្រព័ន្ធថវិកា មិនទទួលបានជោគជ័យតាមការគ្រោងទុក ។ លើសពីនេះ, ការកែទម្រង់ប្រព័ន្ធថវិកាមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងការកែទម្រង់ប្រព័ន្ធអភិបាលកិច្ចសាធារណៈទាំងមូល ដែលក្នុងនោះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនមែនជាកត្តាកំណត់នោះឡើយ ថ្វីត្បិតថាការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាស្នូលដ៏សំខាន់នៃប្រព័ន្ធអភិបាលកិច្ច ។

## ៥- សេចក្តីសន្និដ្ឋាន

ជារួម, *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»*, បើទោះបីជាបានសម្រួលគោលដៅថ្មីក៏ដោយ, បានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតាខ្ពស់ និងបានប្រមើលឃើញជាស្រេចនូវហានិភ័យសំខាន់ៗមួយចំនួន ដែលអាចលើកឡើងនៅក្នុងពេលអនុវត្ត ។ ទោះយ៉ាងនេះក្តី, កម្ពុជាចាំបាច់ត្រូវពុះពារសម្រេចឱ្យបាននូវគោលដៅ ***«ថវិកាព័ត៌មានសមិទ្ធកម្ម»*** ជាសារវ័ន្ត ដើម្បីអាចឆ្លើយតបបានទៅនឹងដំណាក់កាលថ្មីនៃការអភិវឌ្ឍប្រទេសក៏ដូចជានិន្នាការថ្មីៗទាំងឡាយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអន្តរជាតិ ។

ច្បាស់ណាស់ថា, ការគាំទ្រយ៉ាងមុតមាំ និង ការណែនាំជាប្រចាំពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឱ្យការកែទម្រង់ហិរញ្ញវត្ថុសាធារណៈទទួលបានជោគជ័យគួរជាទីមោទនៈ និង កំពុងបន្តមានសន្ទុះទៅមុខ ។ ប្រការនេះ គឺជាកត្តាមិនអាចខ្វះបាន ដែលផ្តល់នូវក្តីសង្ឃឹមដល់កម្ពុជា ក្នុងការកសាងប្រព័ន្ធថវិកាមួយប្រកបដោយ*ប្រសិទ្ធភាព, គណនេយ្យភាព, និង តម្លាភាព,* ស្របតាមឧត្តមានុវត្តអន្តរជាតិ នាឆ្នាំ ២០២៥ ។ លើសពីនេះ, ភាពជាអ្នកដឹកនាំ និង ភាពជាម្ចាស់

ព្រមទាំងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធទាំងអស់ ពោលគឺ របស់គ្រប់ក្រសួង-ស្ថាប័ន, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, គឺជាកត្តាគន្លឹះសម្រាប់ធានាឱ្យបាននូវជោគជ័យនៃការកែទម្រង់ប្រព័ន្ធថវិកា ។

ក្នុងន័យនេះ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្នើសុំការគាំទ្ររបស់រាជរដ្ឋាភិបាលលើសេចក្តីព្រាង **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ ២០១៨-២០២៥»** ដើម្បីបន្តអនុវត្តឱ្យមានប្រសិទ្ធភាព នូវការកែទម្រង់ស៊ីជម្រៅលើការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅកសាងប្រព័ន្ធថវិកាមួយ ប្រកបដោយប្រសិទ្ធភាព, គណនេយ្យភាព, និង តម្លាភាព ។ ជាមួយគ្នានេះ, ខ្ញុំបាទក៏សូមអំពាវនាវផងដែរ ដល់គ្រប់ក្រសួង-ស្ថាប័ន និង តួអង្គពាក់ព័ន្ធទាំងអស់, សូមមេត្តាផ្តល់ការគាំទ្រ និង ចូលរួមអនុវត្ត ដោយបុរេសកម្ម និង សកម្ម ក្នុងស្មារតីម្ចាស់ការ និង ការទទួលខុសត្រូវខ្ពស់ នូវយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ដំណាក់កាលទី ៣ និង ទី ៤ ខាងមុខ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង អង្គគណៈរដ្ឋមន្ត្រី ទាំងមូល មេត្តាពិនិត្យ និង ផ្តល់ការអនុម័ត លើសេចក្តីព្រាង **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥»** ដោយអនុគ្រោះ ។

***សូមអរគុណ !***